## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់
# ក្នុងអំឡុងពេលព្យួរកិច្ចព្រមព្រៀងការងារ

កិច្ចព្រមព្រៀងអំពីនីតិវិធីទូទាត់ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារមានថេរវេលាមិនកំណត់នេះ (ដែលតទៅនេះហៅថា "**កិច្ចព្រមព្រៀង**") ត្រូវបានធ្វើនៅថ្ងៃទី...២៥... ខែវិច្ឆិកា.... ឆ្នាំ២០២០....ដោយ និងរវាងគូភាគី (ហៅជារួមថា "**បណ្តាភាគី**" និងហៅដោយឡែកថា "**ភាគី**")ដូចខាងក្រោម៖

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជី ម៉ាន់នី អ៊ិចឆេន ម.ក G MONEY EXCHANGE PLC. KINGDOM OF CAMBODIA

(១) **ជី ម៉ាន់នី អ៊ិចឆេន ម.ក** គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិតដែលបានចុះបញ្ជីក្រោមលេខ 00050014 ដែលមានទីតាំងស្ថិតនៅ អគារវឌ្ឍនៈកាពីតាល ជាន់ទី១៥, ៦៦មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា តំណាងស្របច្បាប់ដោយលោក **Chen I-Lun** សញ្ជាតិចិនតៃវ៉ាន់ កាន់លិខិតឆ្លងដែនលេខ៣១៤៤៥០១០០ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០១៧ (ដែលតទៅនេះហៅថា "**ក្រុមហ៊ុន**")

**និង**

(២) លោក/លោកស្រី...ចុងចាន់លី..........សញ្ជាតិ...ខ្មែរ.....កាន់អត្តសញ្ញាណប័ណ្ណលេខ......020974433......... ចុះថ្ងៃទី៣១..ខែ០១.....ឆ្នាំ២០១៣.....ហើយមានអាសយដ្ឋាននៅ.នៅផ្ទះ០៦៧...ផ្លូវ២១ ភូមិព្រែកតាកេរ. ស្រុកកោះធំ ខេត្តកណ្តាល ជាតំណាងនិយោជិតនៃក្រុមហ៊ុន (ដែលតទៅនេះហៅថា "**តំណាងនិយោជិត**")

**បុព្វកថា ៖**

(ក) ដោយហេតុថា ការផ្ទុះឡើងជាសកល នៃជម្ងឺកូវីត១៩ ដើម្បីជីវិត និងសុខភាពរបស់និយោជិតរបស់ក្រុមហ៊ុន ព្រមទាំងសហការឲ្យកាន់តែគ្រប់ជ្រុងជ្រោយជាមួយគោលនយោបាយបង្ការ និងគ្រប់គ្រងផ្សេងៗនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតនេះ យោងតាមច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា រួមបញ្ចូលគ្នានឹងស្ថានភាពរាតត្បាតនាពេលបច្ចុប្បន្ន និងស្ថានភាពជាក់ស្តែងរបស់ក្រុមហ៊ុន ។

(ខ) ដោយហេតុថា យោងតាមតម្រូវការនៃសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុន និងដោយមានការព្រមព្រៀងពីនិយោជិត ស្របតាមលក្ខខណ្ឌដូចមានចែងខាងក្រោម ៖

<u>ហេតុដូច្នេះ តាមរយៈការព្រមព្រៀងទាំងសងខាង ក្រុមហ៊ុន និងនិយោជិតយល់ព្រមដូចខាងក្រោម៖</u>

ប្រការ ១ ការព្យួរកិច្ចព្រមព្រៀងការងារ និងការរក្សាតួនាទី

**១.១ វិសាលភាព**

តាមរយៈកិច្ចព្រមព្រៀងនេះ យោងតាមតម្រូវការចាំបាច់ក្រុមហ៊ុន យល់ព្រមអនុញ្ញាតឲ្យ និយោជិតព្យួរការងារ ហើយនិយោជិតយល់ព្រមព្យួរការងារដោយគ្មានប្រាក់បៀវត្សរយៈពេលពីរ(២)ខែ ចាប់ពីថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២០ នេះតទៅ។

**១.៤ ការធានាអះអាង**

និយោជិតត្រូវធានាអះអាងថាខ្លួនមានសេរីភាពស្របច្បាប់ និងសមត្ថភាពពេញលេញក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ បានអាននិងយល់ច្បាស់អំពីខ្លឹមសារក្នុងកិច្ចព្រមព្រៀងនេះ មុនពេលចុះហត្ថលេខា។

ប្រការ ២ រយៈពេលនៃកិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះមានរយៈពេលពីរ(២)ខែ សុពលភាពអនុវត្តចាប់ពីថ្ងៃទី ១ ខែធ្នូ ឆ្នាំ២០២០ រហូតដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ ហើយអាចបន្តសារជាថ្មីដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរពីបណ្ដាភាគី។

ប្រការ ៣ ការទូទាត់ប្រាក់ឈ្នួល

(ក) ក្នុងអំឡុងពេលនៃកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុននឹងមិនផ្តល់ប្រាក់បៀវត្សរ៍ប្រចាំខែជូននិយោជិតនោះទេ។ ក្នុងអំឡុងពេលព្យួរកិច្ចសន្យា តែរក្សាទុកមុខតំណែងដោយគ្មានប្រាក់បៀវត្សនេះ និយោជិតស្ថិតរយៈពេលសាកល្បង ការឈប់សម្រាកប្រចាំឆ្នាំ ការគណនាដែលពាក់ព័ន្ធនឹងប្រាក់អតីតភាព និងអត្ថប្រយោជន៍ផ្សេងទៀតនឹងត្រូវបានផ្អាកផងដែរ។

ខ) ចំពោះប្រាក់ប្រាក់បៀវត្សរ៍របស់និយោជិតសម្រាប់ខែវិច្ឆិកាឆ្នាំ២០២០នេះ នឹងត្រូវបើកជូននិយោជិតទាំងអស់ឲ្យបានយ៉ាងយូរមុនថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ស្របតាមនីតិវិធីបើកប្រាក់តាមស្តង់ដាររបស់ក្រុមហ៊ុន។

ប្រការ ៧ ការបញ្ចប់កិច្ចព្រមព្រៀង

៧.១ ដោយបំពេញនូវកាតព្វកិច្ចរៀងៗខ្លួន កិច្ចព្រមព្រៀងនេះនឹងត្រូវរំលាយនៅពេលដែលមានហេតុការណ៍ណាមួយដូចខាងក្រោមបានកើតឡើង ៖

(ក) ដោយការព្រមព្រៀងរវាងក្រុមហ៊ុន និងនិយោជិត ជាលាយលក្ខណ៍អក្សរ

(ខ) ដោយការបណ្តេញចេញដោយសារកំហុសធ្ងន់របស់និយោជិតដូចដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិនានា របស់ព្រះរាជាណាចក្រកម្ពុជា ដូចបានចែងក្នុងបទបញ្ជាផ្ទៃ ក្នុងនៃមាត្រាទី ៨ និងគោលការណ៍ការងារនានារបស់ក្រុមហ៊ុន។ រាល់ការបំពានលើការព្រមព្រៀងរិតត្បិតដែលចែងដោយប្រការទី ៩ នៃកិច្ចសន្យាការងារមានថេរវេលាមិនកំណត់ នឹងចាត់ទុកថាជាកំហុសធ្ងន់។

(គ) ការលាឈប់ដោយនិយោជិត

(ឃ) ដោយហេតុផលសេដ្ឋកិច្ចដែលបណ្តាលឲ្យមានការបណ្តេញចេញ ដោយស្របតាមច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។

(ង) ដោយករណីប្រធានសក្តិ ដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន។

ប្រការ ១១ ច្បាប់អនុវត្តន៍

គូភាគីបានព្រមព្រៀងថា កិច្ចព្រមព្រៀងនេះនឹងត្រូវបានអនុវត្ត ដោយបកស្រាយ និងអនុលោមតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

ប្រការ ១២ កិច្ចព្រមព្រៀងទាំងមូល

កិច្ចព្រមព្រៀងនេះត្រូវទុកជាកិច្ចព្រមព្រៀងទាំងមូលរវាងគូភាគី ហើយរាល់ការព្រមព្រៀង ឬសេចក្តីថ្លែងការនានាដែលមានមុនកាលបរិច្ឆេទនៃកិច្ចព្រមព្រៀងនេះត្រូវនិរាករណ៍ លើកលែងតែមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ។

ប្រការ ១៣ ការកែប្រែកិច្ចព្រមព្រៀង

រាល់ការកែប្រែ ខ ណាមួយនៃកិច្ចព្រមព្រៀងដែលទាក់ទងនឹងប្រាក់បៀវត្សរ៍ ឬប្រាក់បំណាច់ដោយភាគីណាមួយនៃកិច្ចព្រមព្រៀងនឹងមានអានុភាពគតិយុត្ត លុះត្រាតែត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងចុះហត្ថលេខាដោយភាគីនីមួយៗនៃកិច្ចព្រមព្រៀង ឬអ្នកតំណាងស្របច្បាប់របស់ភាគី។

ដើម្បីជាសក្ខីភាព គូភាគីនៃកិច្ចព្រមព្រៀងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ នៅកាលបរិច្ឆេទដូចមានចែងក្នុងទំព័រដំបូងនៃកិច្ចព្រមព្រៀងនេះ។

**ដោយ ជី ម៉ាន់នី អ៊ិចឆេន ម.ក**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជី ម៉ាន់នី អ៊ិចឆេន ម.ក G MONEY EXCHANGE PLC. KINGDOM OF CAMBODIA

陳億倫

លោក **Chen I-Lun**

តួនាទី៖ **General Manager**

**តំណាងនិយោជិត៖**

លោក /លោកស្រី ចុងចាន់លី